| | **សហគមន៍អណ្ដូង:** ក្រុមការងារតាមផ្ទះ និងមជ្ឈមណ្ឌលផលិតកម្មមួយកំពុងដំណើរការគោលដៅជាក់លាក់សម្រាប់សមាគមន៍អណ្ដូង:<br>**ក្រុមតាមផ្ទះ (សហគមន៍)**<br>- ក្រុមតាមផ្ទះនឹងផ្ដល់សេវាចំនួន ៤០,០០០ ដល់ក្រុមគោលដៅ<br>- កុមារ/យុវវ័យចំនួន ៨០០ នាក់ នៃក្រុមតាមផ្ទះ នឹងទទួលបានសេវាទាំងនោះ<br>- អាណាព្យាបាលចំនួន ៦០០នាក់ នឹងទទួលបានសេវាទាំងនោះ<br>- នឹងមានសមាជិកសុវត្ថិភាពកុមារសកម្មចំនួន ១៥០ នាក់<br><br>**មណ្ឌលសំចត** (ខ្ញុំ និងអ្នក)<br>- ក្រុមតាមផ្ទះនឹងផ្ដល់សេវាចំនួន ៣០,០០០ ដល់ក្រុមគោលដៅ (សង្គ្រោះបឋម បំណិនជីវិត អប់រំក្រៅប្រព័ន្ធ សកម្មភាព កំសាន្តសប្បាយ)<br>- កុមារ/យុវវ័យចំនួន ៣០០ នាក់នៅក្នុងមជ្ឈមណ្ឌល នឹងទទួលបានសេវាទាំងនោះ<br>- អាណាព្យាបាលចំនួន៤០០នាក់ នៅក្នុងមជ្ឈមណ្ឌល នឹងទទួលបានសេវាទាំងនោះ | **សហគមន៍អណ្ដូង:** ក្រុមការងារតាមផ្ទះ និងមជ្ឈមណ្ឌលផលិតកម្មមួយកំពុង ដំណើរការមានទីតាំងក្នុងសង្កាត់គោករកា ។ យើងមានបុគ្គលិកបំរើការចំនួន ១០នាក់ (ស្រី០៣នាក់) ។<br>**ក្រុមតាមផ្ទះ (សហគមន៍)**<br>- ក្រុមតាមផ្ទះបានផ្ដល់សេវាចំនួន ៤៥,២៥៣ (ស្រី ២២,៥៤១) ដល់ក្រុមគោលដៅ<br>- កុមារ/យុវវ័យចំនួន ៧៩៦នាក់ (ស្រី៣១៩នាក់) បានចូលរួមសកម្មភាពក្នុងឆ្នាំ២០១២<br>- អាណាព្យាបាលចំនួន ៣០០នាក់ (ស្រី១៧៩នាក់) បានចូលរួមសកម្មភាពក្នុងឆ្នាំ២០១២<br>- មានសមាជិកសុវត្ថិភាពកុមារសកម្មចំនួន ៧៦នាក់ (ស្រី៤០នាក់) ក្នុងនោះមានសមាជិកសុវត្ថិភាពកុមារសហគមន៍ចំនួន ៥៤ នាក់ (ស្រី៤០នាក់)<br><br>**មណ្ឌលសំចត** (ខ្ញុំ និងអ្នក)<br>- ក្រុមតាមផ្ទះបានផ្ដល់សេវាចំនួន ៥០, ៤៧១ (ស្រី ១៨,៣៣៨នាក់) ដល់ក្រុមគោលដៅ (សង្គ្រោះបឋម បំណិនជីវិត អប់រំក្រៅប្រព័ន្ធ សកម្មភាពកំសាន្តសប្បាយ)<br>- កុមារ/យុវវ័យចំនួន ៣១៣នាក់ (ស្រី១០៧នាក់) បានចូលរួម សកម្មភាព ក្នុងឆ្នាំ២០១២<br>- អាណាព្យាបាលចំនួន ៣៥២នាក់ (ស្រី២០៩នាក់) បានចូលរួម សកម្មភាពក្នុងឆ្នាំ២០១២<br>**ព្រឹត្តិការណ៍ និងកំណត់សម្គាល់ពិសេស:**<br>- មណ្ឌលខ្ញុំ និងអ្នក បានរៀបចំតុបតែងដោយដាក់រូបភាព និងបង្កើតសកម្មភាពថ្មីៗ ដើម្បីទាក់ទាញកុមារនិងយុវវ័យមកទទួលសេវានៅក្នុងមណ្ឌលនឹងប្រែក្លាយមណ្ឌលសំចតទៅ |

| | | |
|---|---|---|
| | | ជាមណ្ឌលយុវវ័យ ហើយបុគ្គលិកមិត្តសំឡាញ់ ក៏បានបត់បែនពេលវេលាធ្វើការទៅតាមតម្រូវការផងដែរ ។ |
| | **មណ្ឌលគ្រឿងញៀនចល័ត:** ផ្ដល់សេវាក្នុងតំបន់ទាំង៥ និងកន្លែងដទៃទៀត<br>គោលដៅជាក់លាក់សម្រាប់មណ្ឌលគ្រឿងញៀនចល័ត :<br>- ក្រុមតាមផ្ទាល់នឹងផ្ដល់សេវាចំនួន ៥០,០០០ ដល់ក្រុមគោលដៅ<br>- កុមារ/យុវវ័យចំនួន ៤០០នៅក្នុងមជ្ឈមណ្ឌលនឹងទទួលបានសេវាទាំងនោះ<br>- កុមារ/យុវវ័យចំនួន ៥០ នាក់នឹងបញ្ជូនទៅមជ្ឈមណ្ឌលបន្សាប | **មណ្ឌលគ្រឿងញៀនចល័ត:** ផ្ដល់សេវាក្នុងតំបន់ទាំង ៤ និងកន្លែងដទៃទៀត<br>គោលដៅជាក់លាក់សម្រាប់មណ្ឌលគ្រឿងញៀនចល័ត :<br>- ក្រុមតាមផ្ទាល់បានផ្ដល់សេវាចំនួន ៧១,៩០៣ ( ស្រី ១០.៤៣៣នាក់) ដល់ក្រុមគោលដៅ<br>- កុមារ/យុវវ័យចំនួន ៥១២នាក់ ( ស្រី ១០៨នាក់) បានចូលរួមសម្មភាពក្នុងមណ្ឌលចល័តក្នុងឆ្នាំ២០១២<br>- កុមារ/យុវវ័យចំនួន ៤៣នាក់ បានបញ្ជូនទៅមជ្ឈមណ្ឌលបន្សាប |
| | **មជ្ឈមណ្ឌលយុវវ័យចល័ត:**( បក្សីឆ្លាត) ផ្ដល់សេវាក្នុងតំបន់ទាំង៥ និងទីតាំង ដទៃទៀត<br>គោលដៅជាក់លាក់សម្រាប់យុវវ័យចល័ត:<br>- ក្រុមតាមផ្ទាល់នឹងផ្ដល់សេវាចំនួន ១១០,០០០ ដល់ក្រុមគោលដៅ<br>- កុមារ/យុវវ័យចំនួន ៧០០ នៅក្នុងមជ្ឈមណ្ឌលនឹងទទួលបានសេវាទាំងនោះ<br>- អាណាព្យាបាលចំនួន ៣៥០នាក់ នឹងទទួលបានសេវាទាំងនោះ | **មជ្ឈមណ្ឌលយុវវ័យចល័ត:**( បក្សីឆ្លាត ) ផ្ដល់សេវាក្នុងតំបន់ទាំង ៤ និងទីតាំងដទៃទៀត<br>- ក្រុមតាមផ្ទាល់បានផ្ដល់សេវាចំនួន ១២៤,៥៣៥ ( ស្រី៥៧,០២១) ដល់ក្រុម គោលដៅ<br>- កុមារ/យុវវ័យចំនួន ៧០២នាក់( ស្រី២៩៦នាក់) បានចូលរួមសកម្មភាពក្នុងឆ្នាំ២០១២<br>- អាណាព្យាបាលចំនួន ៣០១នាក់ ( ស្រី១៩២នាក់) បានចូលរួមសកម្មភាពក្នុងឆ្នាំ២០១២ |
| **៤.២ មណ្ឌលស្នាក់នៅបណ្ដោះអាសន្ន** | - **មណ្ឌលស្នាក់នៅបណ្ដោះអាសន្ន**ចំនួន ៣ កំពុងផ្ដល់កន្លែងស្នាក់នៅដ៏មានសុវត្ថិភាពដល់កុមារ/យុវវ័យ ជាអតិបរមារហូតដល់ ៥០០នាក់ ក្នុងមួយឆ្នាំ<br>- ការចូលរួមរបស់កុមារត្រូវបានធានាយ៉ាងជាក់ច្បាស់តាមរយៈការប្រជុំទូទៅជារៀងរាល់សប្ដាហ៍ តាមការបោះឆ្នោត និង តាមប្រអប់សំបុត្រសំណើរដែលមាននៅតាមមណ្ឌលស្នាក់នៅបណ្ដោះអាសន្នទាំងអស់<br>- សេវាចំនួន ៨០,០០០ នៃសកម្មភាពកម្សាន្ត ទស្សនកិច្ច ការចូលរួមរបស់កុមារ ការសួរសុខទុក្ខ ការការពារកុមារ អាហារពេលព្រឹក បានផ្ដល់ដល់កុមារ/យុវវ័យ | **មណ្ឌលស្នាក់នៅបណ្ដោះអាសន្ន** ជាកន្លែងស្នាក់នៅបណ្ដោះអាសន្ន ប្រកបដោយសុវត្ថិភាពសម្រាប់កុមារ និងយុវវ័យ កំឡុងពេលសិក្សារបស់ពួកគេ ។<br>- មណ្ឌលស្នាក់នៅបណ្ដោះអាសន្នចំនួន ៣ កំពុងផ្ដល់កន្លែងស្នាក់នៅដ៏មានសុវត្ថិភាពដល់កុមារ/យុវវ័យ ៥៤៤នាក់ ( ស្រី១២៦នាក់) ដែលមានទីតាំងក្នុងសង្កាត់ទឹក ល្អក់ទី ៣ សង្កាត់ទំនប់ទឹក និងសង្កាត់ទួលស្វាយព្រៃ១ ក្នុងឆ្នាំ ២០១២ ។<br>- កុមារ/យុវវ័យបានចូលរួមការប្រជុំទូទៅ ជារៀងរាល់សប្ដាហ៍ និងបើកប្រអប់សំបុត្រសំណើរចំនួន ២ដងក្នុងមួយខែ នៅមណ្ឌលស្នាក់នៅបណ្ដោះអាសន្នទាំងអស់ ។ |

| | | |
|---|---|---|
| | នៅក្នុង មណ្ឌលទាំងអស់ ក្នុងនោះមានសេវាព្យាបាលចំនួន ៩,000 ដង ។<br>- កុមារ/យុវវ័យចំនួន ៦៥0នាក់ មកពីតាមផ្ទល់ និងមណ្ឌលស្នាក់នៅបណ្តោះអាសន្ន នឹងបាន ចូលរួមសកម្មភាពនៅ ជុំរសប្បាយ នៅខេត្តកំពង់ស្ពឺ ក្នុងមួយឆ្នាំ | - សេវាចំនួន ២៤,0៨៦ នៃសកម្មភាពកម្សាន្ត ទស្សនកិច្ច ការចូលរួមរបស់កុមារ ការសួរសុខទុក្ខ ការការពារកុមារ បានផ្តល់ដល់កុមារ/យុវវ័យនៅក្នុងមណ្ឌលទាំងអស់ ក្នុងនោះមានសេវាព្យាបាលចំនួន ៨,៦១៤ ដង ។<br>- កុមារ/យុវវ័យមកពីតាមផ្ទល់ និងមណ្ឌលស្នាក់នៅបណ្តោះអាសន្នចំនួន៣២៤នាក់ ( ស្រី ៨៤ នាក់) បានចូល រួមសកម្មភាព នៅជុំរសប្បាយសប្បាយ ខេត្តកំពង់ស្ពឺក្នុងឆ្នាំ២០១២ ។<br>**ព្រឹត្តិការណ៍ និងកំណត់សម្គាល់ពិសេស:**<br>- បានរៀបចំពិធីជប់លៀងសម្រាប់កុមាររនៅមណ្ឌលស្នាក់នៅបណ្តោះអាសន្នទាំង៣ នៅថ្ងៃបុណ្យចូលឆ្នាំប្រពៃណីខ្មែរ នាថ្ងៃទី 0៤ ខែមេសា ឆ្នាំ២០១២ ។<br>- កុមារ/យុវវ័យចំនួន ១៩ នាក់ ( ស្រី 0៦នាក់) បានចូលរួមទិវាសិទ្ធិកុមារអន្តរជាតិលើកទី៦៣ នៅកោះពេជ្រ រៀបចំដោយគណៈកម្មាធិការអង្គការមិនមែនរដ្ឋាភិបាល នា ថ្ងៃទី ២៩ ខែឧសភា ឆ្នាំ២០១២ ។<br>- កុមារ/យុវវ័យចំនួន ១៧ នាក់( ស្រី0២នាក់) បានទៅបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ/សង្កាត់ នៅឯស្រុកកំណើតរបស់ពួកគេ នាថ្ងៃទី 0៣ ខែមិថុនា ឆ្នាំ២០១២ ។<br>- កុមារ/យុវវ័យចំនួន ៣0នាក់ ( ស្រី 0៩នាក់) បានចូលរួមទិវាប្រយុទ្ធប្រឆាំងគ្រឿង ញៀន នៅពហុកីឡដ្ឋានជាតិអូឡាំពិក រៀបចំដោយអាជ្ញធរជាតិប្រយុទ្ធប្រឆាំគ្រឿងញៀន នាថ្ងៃទី ២៦ ខែមិថុនា ឆ្នាំ២០១២ ។<br>- បុគ្គលិកមណ្ឌលស្នាក់នៅបណ្តោះអាសន្ន ១0នាក់( ស្រី 0៦នាក់) បានចូលរួមវគ្គបណ្តុះបណ្តាលស្តីពីការអភិវឌ្ឍន៏កុមារពិការ សិល្បៈកែច្នៃ និងបទដ្ឋានអប្បបិរមារបស់ក្រសួងសង្គមកិច្ច អតីតយុទ្ធ និងយុវនីតិសម្បទា ដោយអង្គការដៃគូ ។<br>- សេវាកម្សាន្តខាងក្រៅចំនួន ៦២៥ បានរៀបចំដល់កុមារ/យុវវ័យនៅទីកន្លែងផ្សេងៗ គ្នា |

| | | |
|---|---|---|
| | | រួមមាន មហោស្រពចេនឡា ទូរទស្សន៍ស៊ីធីអិន សាលមហោស្រពកោះពេជ្រ វិទ្យាស្ថានបារាំងនៅកម្ពុជា ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ រមណីយដ្ឋានភ្នំតាម៉ៅ ពហុកីឡាដ្ឋានជាតិអូឡាំពិក មជ្ឈមណ្ឌលសៀក អង្គការផ្ទះមេត្តា ជុំសប្បាយសប្បាយ និងអង្គការភាពញញឹមនៃកុមារ ។ |
| ៤.៣ កម្មវិធីអប់រំ | **មជ្ឈមណ្ឌលអប់រំ:**<br>- មជ្ឈមណ្ឌលអប់រំ កំពុងផ្តល់ការអប់រំបំប៉នកម្រិតបឋមសិក្សាដល់កុមារ ៥០០ នាក់ក្នុងមួយឆ្នាំ<br>- ត្រៀមរៀបចំធ្វើសមាហរណកម្មកុមារចំនួន ៣០០ នាក់ទៅសាលារដ្ឋក្នុងមួយឆ្នាំ<br>- នឹងរៀបចំការប្រជុំជាមួយមាតាបិតា ៤លើក ដើម្បីត្រៀមធ្វើការបញ្ជូលទៅក្នុងសាលារដ្ឋ ក្នុងមួយឆ្នាំ<br>- កុមារចំនួន ១,១០០នាក់ នឹងទទួលបានការគាំទ្រដើម្បីបន្តការសិក្សានៅសាលារដ្ឋក្នុងមួយឆ្នាំ<br>- កុមារចំនួន ៥០នាក់ នឹងបានចូលរៀនថ្នាក់បំប៉ន បន្ទាប់ពីការបញ្ជូនទៅសាលារដ្ឋក្នុងមួយឆ្នាំ | - **មជ្ឈមណ្ឌលអប់រំ** ផ្តល់សកម្មភាពអប់រំបំប៉នកម្រិតបឋមសិក្សាដើម្បីសម្របសម្រួលលើការសមាហរណកម្មសិស្សទៅសាលារដ្ឋ និងផ្តល់ការអប់រំជាមូលដ្ឋានដល់កុមារ/ យុវវ័យដែលធ្វើការតាមផ្លូវ ។<br>- មជ្ឈមណ្ឌលអប់រំបានផ្តល់ការអប់រំបំប៉នកម្រិតបឋមសិក្សាដល់កុមារ ៣៩៦នាក់ (ស្រី ១៧២នាក់) នាក់ នៅមជ្ឈមណ្ឌលអប់រំ ក្នុងឆ្នាំ ២០១២ ។<br>- កុមារចំនួន ៣៧៦នាក់ (ស្រី១៦០នាក់) បានគាំទ្រនិងធ្វើសមាហរណកម្ម ទៅសាលារដ្ឋ ។<br>- មាតាបិតាបានចូលរួមប្រជុំ ៤ដង ដើម្បីចែកចាយព័ត៌មាន នៃការសិក្សារបស់កុមារនៅមជ្ឈមណ្ឌលអប់រំ និងរៀបចំធ្វើសមាហរណកម្មទៅ សាលារដ្ឋក្នុងឆ្នាំ២០១២ ។<br>- កុមារចំនួន ១,២៣៧នាក់ (ស្រី៥១៦នាក់) បានទទួលការគាំទ្រដើម្បីបន្តការសិក្សានៅសាលារដ្ឋនៅរាជធានីភ្នំពេញ ។<br>- កុមារចំនួន ៤២នាក់ (ស្រី១៨នាក់) បានចូលរៀនថ្នាក់បំប៉ន បន្ទាប់ពីការបញ្ជូនទៅសាលារដ្ឋក្នុងឆ្នាំនេះ ។<br>**ព្រឹត្តិការណ៍ និងកំណត់សម្គាល់ពិសេស:**<br>- ថ្នាក់អប់រំក្រៅប្រព័ន្ធបានបង្កើតឡើងនៅថ្ងៃទី ២១ ខែវិច្ឆិកា ឆ្នាំ២០១២ ដោយមានកុមារ/ យុវវ័យចំនួន ៤១នាក់ (ស្រី២៧នាក់) បានចូលរួមនៅសហគមន៍អណ្តូង ។<br>- កុមារចំនួន ២៦៨នាក់ (ស្រី១៤២នាក់) មកពីអង្គការនីញ៉ូម៉ូ បានចូលរួមសកម្មភាព |

| | | |
|---|---|---|
| | | បណ្ណាល័យនៅអង្គការមិត្តសំឡាញ់ ។<br>- កុមារចំនួន ២៣២នាក់( ស្រី ៩៨នាក់) បានទទួលការពិនិត្យធ្មេញរបស់ពួកគេ នៅ អង្គការ ONE-2- ONE Cambodia ។<br>- កុមារចំនួន ៤០នាក់( ស្រី១៤នាក់) បានទទួលការបន្តក់ថ្នាំវីតាមីនអា ពីក្រសួងសុខាភិបាល នៅមិត្តសំឡាញ់ នាថ្ងៃទី ២៤ ខែឧសភា ឆ្នាំ២០១២ ។<br>- បុគលិកមិត្តសំឡាញ់ចំនួន ០១នាក់ បានចូលរួមទិវាអក្ខរកម្មនៅទីក្រុងតាខ្មៅខេត្តកណ្ដាល រៀបចំដោយក្រសួងអប់រំយុវជន និងកីឡា នាថ្ងៃទី០៨ ខែកញ្ញា ឆ្នាំ២០១២ ។<br>- មន្ត្រីតាមដានករណី បានធ្វើពិធីចែកសម្ភារៈសិក្សាដល់កុមារដែលត្រូវបន្តការសិក្សានៅសាលារដ្ឋមានការចូលរួមជាអធិបតី ដោយអនុប្រធានមន្ទីរសង្គមកិច្ចអតីតយុវជន យុវនីតិសម្បទា នៅក្លឹបប្រៀន្យ នាថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០១២ ។<br>- បុគ្គលិកមិត្តសំឡាញ់ គ្រូអក្ខរកម្ម គ្រូបឋមសិក្សា អង្គការដៃគូ រួមមាន ស៊ីប៉ា អង្គការប្រតិបត្តិការកុមារកម្ពុជាចំនួន ២៤៣ នាក់( ស្រី១១៣នាក់) បានទទួលវគ្គបណ្ដុះបណ្ដាល ស្ដីពីឧបករណ៍សិក្សា នៅខេត្តចំនួន៣ រួមមាន រាជធានីភ្នំពេញ បាត់ដំបង និង កណ្ដាល ។<br>- កុមារចំនួន ៣០នាក់ ( ស្រី១៨នាក់) បានលេងល្បែងកម្សាន្ត និងចូលរួមសកម្មភាពជា មួយកុមារមកពីសាលាអន្តរជាតិភ្នំពេញ ដើម្បីបង្កើតចំណងមិត្តភាព ។<br>- កុមារចំនួន ១២៧នាក់ (ស្រី ៦១នាក់) បានចូលរួមសកម្មភាពនៅខាងក្រៅ រួមមាន ទស្សនារឿងគំនូរជីវចល ការតាំងពិព័ណ៌រូបភាព និងបណ្ណាល័យ ។ |
| | **មជ្ឈមណ្ឌលបណ្ដុះបណ្ដាលវិជ្ជាជីវៈ** (ថ្នាក់ជំនាញ និងអាជីវកម្ម) កំពុងផ្ដល់ជំនាញវិជ្ជាជីវៈផ្សេងៗគ្នា ដល់កុមារចំនួន ៦០០នាក់ ក្នុងមួយឆ្នាំ និងជួយពួកគេឱ្យ | **មជ្ឈមណ្ឌលបណ្ដុះបណ្ដាលវិជ្ជាជីវៈ** ផ្ដល់ការបណ្ដុះបណ្ដាលដ៏មានគុណភាពនាំមុខគេលើជំរើសការងារដ៏បិតថេរសម្រាប់យុវវ័យ ។ អង្គការមិត្តសំឡាញ់មាន ០៩ ជំនាញ ផ្សេងៗ |

| | | |
|---|---|---|
| | មានការងារធ្វើ (ដោយមានយុវវ័យជាស្រីចំនួន ៣០%) នឹងផ្តល់គាំទ្រពួកគេ ដើម្បីសមាហរណកម្ម ទៅធ្វើការ និងបង្កើតអាជីវកម្មខ្នាតតូច<br>- យុវវ័យចំនួន ១២០នាក់ នឹងទទួលបានការបណ្តុះបណ្តាលវិជ្ជាជីវៈ បន្ទាប់ពីបានបញ្ចប់ការសិក្សាយ៉ាងហោចណាស់មួយកម្រិតពីមជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈក្នុង១ ឆ្នាំ<br>- នឹងផ្តល់សេវាអប់រំក្រៅប្រព័ន្ធដល់យុវវ័យ នៅមជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈ ចំនួន ២០០,០០០ ដង (ភាសាអង់គ្លេស រៀនអក្សរ បំណិនជីវិត កុំព្យូទ័រ ការងារ ការគ្រប់គ្រង់ករណី ការព្យាបាល អាហារថ្ងៃត្រង់ និងការបណ្តុះបណ្តាល) ។<br>- នៅឆ្នាំ២០១៥ អត្រានៃការបោះបង់ការសិក្សានៅមជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈ នឹងមានការធ្លាក់ចុះរហូតដល់ ១០% (ផ្អែកលើរបាយការណ៍ឆ្នាំ ២០១១)*<br>- យុវវ័យ ចំនួន ១០នាក់ បានគាំទ្រឱ្យរស់នៅឯករាជ្យជាក្រុម កំឡុងពេលសិក្សារបស់ពួកគេនៅអង្គការមិត្តសំឡាញ់<br><br>- យុវវ័យ ១៥០នាក់ នឹងទទួលបានជួយស្វែងរកការងារឱ្យធ្វើរឺបង្កើតរបរដោយខ្លួនឯង នៅភ្នំពេញក្នុងមួយឆ្នាំ<br>- យុវវ័យចំនួន ៣០ នាក់ នឹងគាំទ្រឱ្យរកស៊ីដោយខ្លួនឯង និងរស់នៅឯករាជ្យ<br>- បន្ទាប់ពីការធ្វើសមាហរណកម្មរយៈពេល ៦ខែ នឹងមានយុវវ័យ ៨០ % កំពុងបំរើការងារ ឬប្រកបរបរដោយខ្លួនឯង<br>- បណ្តុះបណ្តាលអាជីវកម្មជំនាញវិជ្ជាជីវៈនឹងទទួលបានប្រាក់ចំណូលចំនួន ៤៥,០០០ ដុល្លារក្នុងមួយឆ្នាំ<br>- ភោជនីដ្ឋានចំនួន២ នឹងបង្កើនប្រាក់ចំនូល១,១៥៤,០០០ដុល្លារ ជាមួយប្រាក់ចំណេញ ៣៣៨,០០០ នាក់ ក្នុង១ឆ្នាំ | គ្នា។<br>- បានផ្តល់ការបណ្តុះបណ្តាលវិជ្ជាជីវៈផ្សេងៗគ្នាដល់យុវវ័យចំនួន៥៧៧នាក់ (ស្រី ១៤៧នាក់) និង ១៣៨នាក់ (ស្រី ៣០នាក់) បានគាំទ្រអោយទៅធ្វើការងារ និងបង្កើតមុខរបរដោយខ្លួនឯង ក្នុងឆ្នាំ២០១២។<br>- យុវវ័យចំនួន ៩៦នាក់ (ស្រី១៨នាក់) បានមកទទួលការបណ្តុះបណ្តាលវិជ្ជាជីវៈហើយបានបញ្ចប់ការសិក្សាយ៉ាងហោចណាស់កំរិតទីមួយពីមជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជា ជីវៈ ក្នុងឆ្នាំ ២០១២។<br>- សេវាអប់រំចំនួន១៥៣,៦៣៦ ដង (ស្រី៤៣,៨៦៨ ដង) រួមមាន បំណិនជីវិត កុំព្យូទ័រ និង ការព្យាបាល បានផ្តល់ដល់យុវវ័យនៅមជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈ ។<br>- យុវវ័យចំនួន ៩៧នាក់ (ស្រី១៦នាក់) បានបោះបង់ចោលការសិក្សានៅមជ្ឈមណ្ឌល បណ្តុះបណ្តាលវិជ្ជាជីវៈ ហើយមិនត្រឡប់មកចូលរៀនវិញនៅក្នុងកំឡុងពេលធ្វើរបាយការណ៍នេះ)* អត្រានៃការបោះបង់ការសិក្សាក្នុងឆ្នាំ២០១១មានចំនួន ២០ % ប៉ុន្តែក្នុងឆ្នាំ ២០១២ អត្រានៃការបោះបង់ការសិក្សាមានត្រឹម ១៨% ថយចុះ ។<br>- យុវវ័យចំនួន ១៦នាក់ (ស្រី ០៥នាក់) បានគាំទ្រឱ្យរស់នៅឯករាជ្យជាក្រុមកំឡុង ពេលសិក្សារបស់ពួកគេនៅអង្គការមិត្តសំឡាញ់ ។<br>- យុវវ័យចំនួន ៩៩នាក់ (ស្រី២៨នាក់) បានជួយស្វែងរកការងារឱ្យធ្វើ រឺបង្កើតមុខរបរដោយខ្លួនឯងរួមទាំងកុមារ ៤៩នាក់ (ស្រី០៣នាក់) បានគាំទ្រឱ្យរស់នៅឯករាជ្យនៅរាជធានីភ្នំពេញ ក្នុងឆ្នាំ២០១២។<br>- បន្ទាប់ពីការធ្វើសមាហរណកម្មរយៈពេល ៦ខែមានយុវវ័យ ៨៦ % កំពុងបន្ត បំរើការងារ ឬប្រកបរបរដោយខ្លួនឯង ។ |

| | | |
|---|---|---|
| | **ភោជនីដ្ឋានប្រេងឡុះ** ៦២៧,000ដុល្លារ (កើនឡើង ១.៥%ពីឆ្នាំ ២០១១) ប្រាក់ចំណេញៈ ២១១,000 ដុល្លារ<br>**ភោជនីដ្ឋានរំដេងៈ** ៥២៧,000ដុល្លារ (កើនឡើង ១០ %ពីឆ្នាំ ២០១១) ប្រាក់ចំណេញ ១២៧,000 ដុល្លារ | - បណ្តុះបណ្តាលអាជីវកម្មជំនាញវិជ្ជាជីវៈទទួលបានប្រាក់ចំណូល ៥២.៤៨៧.៨៤ ដុល្លារ ក្នុងឆ្នាំនេះ ។<br>- ភោជនីដ្ឋានចំនួន២ បានបង្កើនប្រាក់ចំណូល ១,១៥១,៥២៩,៣៧ដុល្លារ និងចំណេញចំនួន ២២៣,៤៧៧.០៣ដុល្លារ ក្នុងឆ្នាំនេះ ។<br>**ភោជនីដ្ឋានប្រេងឡុះ** ៦០៨ ,៩00.៤0ដុល្លារ ប្រាក់ចំណូល និងចំណេញ ១៤៥,១០៣.0២ ដុល្លារ<br>**ភោជនីដ្ឋានរំដេងៈ** ៥៤២,៦២៨.៩៧ ដុល្លារ ប្រាក់ចំណូល និងចំណេញ ៧៨,៣៧៤.0១ ដុល្លារ ។<br>**ព្រឹត្តិការណ៍ និងកំណត់សម្គាល់ពិសេសៈ**<br>- សិស្សានុសិស្សចំនួន ៣0នាក់ និងបុគ្គលិកចំនួន 0៦ នាក់ បានទៅទស្សនកិច្ចសិក្សា នៅមជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈដុនបូស្កូ និងអង្គការភាពញញឹមនៃកុមារ ។<br>- បានចូលរួមសិក្ខាសាលាស្តីពី ពិនិត្យសម្ភារៈអប់រំឡើងវិញលើការងារទេសចរណ៍ រៀបចំដោយក្រសួងទេសចរណ៍ នៅសណ្ឋាគារភ្នំពេញ នាថ្ងៃទី0៦ ខែកក្កដា ឆ្នាំ២០១២ ។<br>- បានចូលរួមសិក្ខាសាលា ស្តីពីលទ្ធផលនៃការប្រមូលទិន្នន័យរបស់មណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈ រៀបចំដោយក្រសួងការងារ នៅសណ្ឋាគារភ្នំពេញ នាថ្ងៃទី៣១ ខែកក្កដា ឆ្នាំ ២០១២ ។<br>- បានចូលសិក្ខាសាលាស្តីពីការចុះបញ្ជី នៅក្នុងវិទ្យាស្ថានបណ្តុះបណ្តាលវិជ្ជាជីវៈ រៀបចំដោយក្រសួងការងារ នៅវិទ្យាស្ថានជាតិបណ្តុះបណ្តាលបច្ចេកទេស នាថ្ងៃទី0១ ខែ សីហា ឆ្នាំ២០១២ ។<br>- យុវវ័យចំនួន ១១២នាក់ (ស្រី២0នាក់) បានទទួលវិញ្ញាបនបត្រ បណ្តុះបណ្តាលវិជ្ជាជីវៈ |

| | | |
|---|---|---|
| | | នៅឆ្នាំ២០១២ ដោយមានការទទួលស្គាល់ពីក្រសួងសង្គមកិច្ចអតីតយុទ្ធ និងយុវនីតិសម្បទា ។ |
| | - **ក្លឹបប្រេន្ទ្យ:** កំពុងផ្តល់សេវាសកម្មភាពផ្នែកវប្បធម៌ផ្សេងៗ ចំនួន ១០០,០០០ រួមមាន រាំ ល្ខោន បណ្ណាល័យ គំនូរ ដល់កុមារទាំងអស់នៅមជ្ឈមណ្ឌលអប់រំ និងមជ្ឈមណ្ឌល បណ្តុះបណ្តាលវិជ្ជាជីវៈ ក្នុងមួយឆ្នាំ<br>- ក្លឹបប្រេន្ទ្យនឹងបើកសម្រាប់កុមារ/យុវវ័យនៅតាមថ្នល់ចំនួន ២ ដងក្នុងមួយសប្តាហ៍ ដោយផ្តល់សេវានៃសកម្មភាពផ្នែកវប្បធម៌ និងកីឡាចំនួន ៣,៥០០ដង ដល់ពួកគេ<br>- ក្លឹបប្រេន្ទ្យកំពុងរៀបចំសកម្មភាពទៅខាងក្រៅសម្រាប់កុមារ និងយុវវ័យនៅក្នុងមជ្ឈមណ្ឌលអប់រំ និងមជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈដោយផ្តល់សេវាកម្មចំនួន ១,២០០ ក្នុងមួយឆ្នាំ | **ក្លឹបប្រេន្ទ្យ:** ជាមណ្ឌលអប់រំរបស់អង្គការមិត្តសំឡាញ់ ដែលកុមារ/យុវវ័យអាចអនុវត្តសកម្មភាពកម្សាន្តសប្បាយ និងវប្បធម៌ រួមមាន កីឡា គំនូរ ផាត់ពណ៌ បណ្ណាល័យ រាំ និងតន្ត្រី ។<br>- ក្លឹបប្រេន្ទ្យកំពុងផ្តល់សេវាផ្នែកវប្បធម៌ផ្សេងៗ ចំនួន ១២៣,៥៥៥ ដង (ស្រី៤៦,៩៨៩ ដង) រួមមាន វប្បធម៌ សកម្មភាពខាងក្រៅ/កម្សាន្ត អប់រំបំណិនជីវិត ដល់កុមារ ទាំងអស់ នៅមជ្ឈមណ្ឌលអប់រំ មជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈ ព្រមទាំងកុមារនៅតាមថ្នល់ ។<br>- ក្លឹបប្រេន្ទ្យ បានបើកសម្រាប់កុមារ/យុវវ័យមកពីក្រៅចំនួន ២ដងក្នុងមួយសប្តាហ៍ ដោយផ្តល់សេវាបំណិនជីវិត ចំនួន ៥,០៣៦ដង (ស្រី៨០៤ដង) ដល់ពួកគេ ។<br>- ក្លឹបប្រេន្ទ្យ បានរៀបចំសកម្មភាពទៅខាងក្រៅសម្រាប់កុមារនិងយុវវ័យ នៅក្នុងមជ្ឈមណ្ឌលអប់រំ និងមជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈដោយផ្តល់សេវាកម្មចំនួន ១,៨៤៩ដង (ស្រី ៦៦៣ដង) ដូចជាសេវា កីឡា ព្រឹត្តិការណ៍វប្បធម៌ ទស្សនាព្រះបរមរាជវាំង សារៈមន្ទីជាតិ និងសកម្មភាពពិសេសខាងក្រៅ ។<br>**ព្រឹត្តិការណ៍ និងកំណត់សម្គាល់ពិសេស:**<br>- កុមារ/យុវវ័យចំនួន ៤៥០នាក់ (ស្រី១៤៧នាក់) បានចូលរួមការប្រកួតកីឡានៅខាងក្រៅ និងខាងក្នុង ក្នុងឆ្នាំនេះ រួមមាន កីឡាបាល់ទាត់ បាល់បោះ វាយកូនឃ្លីលើតុ បាល់អោប... ។ល។<br>- យុវវ័យ ៥៤នាក់(ស្រី៣៦នាក់) បានចូលរួមប្រឡងចំរៀង និងដើរបង្ហាញម៉ូត នៅ |

| | | |
|---|---|---|
| | | ទូរទស្សន៍ហង្សមាស និង ទូរទស្សន៍អាស៊ីអាគ្នេយ៍ ។<br>- កុមារ/យុវវ័យចំនួន ២៨៥ នាក់( ស្រី ៨៦នាក់) បានចូលរួមសម្តែងទិវានៃក្តីស្រឡាញ់ ទិវា សិទ្ធិកុមារអន្តរជាតិ ទិវាប្រយុទ្ធប្រឆាំងគ្រឿងញៀន ហ្វាន់ហ្វ៊ែរ មហោស្រពសិល្បៈ យុវជន និង ទិវាជម្ងឺអេដស៍លើពិភពលោក ។<br>- កុមារ/យុវវ័យ ៥៣នាក់ (ស្រី២៨នាក់) បានចូលរួមបង្កើតសម្ភារៈតាំងពិព័ណ៌ស្តីពី ចរន្តទីក្រុង នាថ្ងៃទី ២៩ ខែកញ្ញា ឆ្នាំ២០១២ ។<br>កុមារ/យុវវ័យចំនួន ២៨៩ នាក់ ( ស្រី១៣៤នាក់) បានទៅទស្សនា នៅសារមន្ទីរទួលស្លែង មហោស្រពចតុមុខ ផ្សារទំនើបសូរិយា វិទ្យាសាស្ត្របារាំងនៅកម្ពុជា ផ្ទះមេត្តា និង ព្រះបរមរាជវាំង ដើម្បីពង្រឹងការយល់ដឹងរបស់ពួកគេក្រៅពីការសិក្សានៅក្នុងថ្នាក់ ។ |
| **៤.៤ ក្រុមសមាហរណកម្ម**<br>ផ្តល់ការគាំទ្រ ដល់កុមារ ២00 នាក់ក្នុងមួយ ឆ្នាំ ដើម្បីសមាហរណកម្ម ទៅកាន់គ្រួសារ ( គ្រួសារបង្កើត គ្រួសារសាច់ញាតិ និងគ្រួសារធម៌) នៅតាមបណ្តាខេត្តនានា ។ | **សមាហរណកម្ម:**<br>- បទដ្ឋាននៃនិតិវិធីលើសមាហរណកម្ម (SoPs) នឹងកែលំអ បកប្រែ និងដំណើការ ដោយក្រុមការងារនៅចុងឆ្នាំ ២០១២ ។<br>- កិច្ចសហការជាមួយរាជរដ្ឋាភិបាល និងអង្គការដៃគូត្រូវបានចាប់ផ្តើមតាមរយៈការប្រជុំ និងការបណ្តុះបណ្តាល<br>- នឹងរៀនចំប្រជុំគណៈកម្មាធិការគ្រួសារធម៌ ចំនួន ៤ ដងក្នុង១ ឆ្នាំ<br>- កុមារចំនួន ១00 នាក់ បានគាំទ្រលើការសមាហរណកម្មគ្រួសាររបស់ពួកគេ (រួមបញ្ចូលគ្រួសារផ្ទាល់ គ្រួសារសាច់ញាតិ )ឬរស់នៅឯករាជ្យនៅក្នុង ខេត្តរបស់ពួកគេ ក្នុង១ឆ្នាំ<br>- កុមារចំនួន១0នាក់ នឹងទទួលបានគាំទ្រលើការសមាហរណកម្មទៅកាន់គ្រួសារធម៌ ក្នុង១ឆ្នាំ | **សមាហរណកម្ម:**<br>- បទដ្ឋាននៃនិតិវិធីលើសមាហរណកម្មសំរេចបាន ៩0% ហើយនឹងបញ្ចប់នៅឆ្នាំ២០១៣<br>- នៅតែបន្តការសហការជាមួយមន្ទីរសង្គមកិច្ចរាជធានី/ខេត្ត និងអង្គការដៃគូលើការងារ សមាហរណកម្ម រួមមាន ការស្វែងរក ការប៉ាន់ប្រមាណ ផែនការគ្រួសារ សមាហរណកម្ម និងការតាមដាននៅ ២៤ខេត្ត/ក្រុង ។<br>- បានចូលរួមប្រជុំ ២ដងដើម្បីចែកចាយព័ត៌មានក្នុងការធ្វើសមារណកម្មកុមារ និងពង្រឹង ការសហការរវាងក្រសួងស.អ.យ និងមិត្តសំឡាញ់នៅក្រសួងក្នុងឆ្នាំ២០១២ ។<br>- បានរៀបចំប្រជុំគណៈកម្មាធិការគ្រួសារធម៌ចំនួន ៤ដង ស្តីពីការបង្កើតទម្រង់សមាជិក នៅក្រសួងស.អ.យ ក្នុងឆ្នាំ២០១២នេះ ។<br>- កុមារចំនួន ១២១នាក់ ( ស្រី ២៣នាក់) បានគាំទ្រលើការសមាហរណកម្មទៅកាន់គ្រួសារ ផ្ទាល់ គ្រួសារសាច់ញាតិ និង រស់នៅឯករាជ្យ នៅក្នុងខេត្តរបស់ពួកគេ ក្នុងឆ្នាំ២០១២ ។ |

| | | |
|---|---|---|
| | - កុមារចំនួន ៥០នាក់ នឹងទទួលបានគាំទ្រលើការសមាហរណកម្មទៅសាលារដ្ឋក្នុងខេត្តរបស់គេក្នុង១ឆ្នាំ ។<br>- កុមារចំនួន ៣០០ នាក់ នៅសាលារដ្ឋ នឹងទទួលបានការគាំទ្រដើម្បីបន្តការសិក្សានៅសាលារដ្ឋក្នុងខេត្តរបស់ពួកគេ ក្នុង១ឆ្នាំ<br>- យុវវ័យចំនួន ២០នាក់ នឹងជួយស្វែងរកការងារឱ្យធ្វើ រឺបង្កើតមុខរបរ ដោយខ្លួនឯងនៅខេត្តរបស់ពួកគេ ក្នុង១ឆ្នាំ<br>- យុវវ័យចំនួន ៧០ នាក់នឹងត្រូវបានតាមដានលើការងារឬការចាប់ផ្តើមអាជីវកម្មផ្ទាល់ខ្លួនរបស់ពួកគេនៅក្នុងខេត្តរបស់ពួកគេក្នុង១ឆ្នាំ<br>- គ្រួសាររស់នៅតាមផ្លូវចំនួន ១៥ គ្រួសារ នឹងទទួលបានគាំទ្រឱ្យត្រឡប់ទៅស្រុកកំណើតវិញក្នុង ១ឆ្នាំ<br>- គ្រួសារចំនួន១០ នឹងទទួលបានការបណ្តុះបណ្តាល និងគាំទ្រសំរាប់អាជីវកម្មខ្នាតតូចនៅក្នុងខេត្តរបស់ពួកគេក្នុង១ឆ្នាំ<br>- កុមារ/យុវវ័យចំនួន ២៥នាក់ នឹងទទួលបានគាំទ្រក្នុងការទទួលអត្តសញ្ញាណប័ណ្ណ សំបុត្រកំណើត នៅខេត្តរបស់ពួកគេក្នុង១ឆ្នាំ | - កុមារចំនួន ១១នាក់(ស្រី០២នាក់)ក្នុងនោះមានថ្មីចំនួន ០៤នាក់ (ស្រី០១នាក់) ក្នុងឆ្នាំ២០១២ បានគាំទ្រលើការចិញ្ចឹមរយៈពេលខ្លី និងរយៈពេល វែង នៅខេត្ត និង ភ្នំពេញ ។<br>- កុមារចំនួន ៦៥ នាក់(ស្រី២០នាក់) បានទទួលការគាំទ្រដើម្បីបន្តការសិក្សានៅ សាលារដ្ឋក្នុងខេត្តរបស់ពួកគេ និងទទួលបានសម្ភារៈសិក្សា ក្នុងឆ្នាំ២០១២ ។<br>- កុមារចំនួន ៣១០នាក់(ស្រី១១២នាក់) បានទទួលការគាំទ្រដើម្បីបន្តការសិក្សានៅ សាលារដ្ឋក្នុងខេត្តរបស់ពួកគេ និងទទួលបានសម្ភារៈសិក្សាក្នុងឆ្នាំ២០១២ ។<br>- យុវវ័យចំនួន ៣៩នាក់(ស្រី០២នាក់)បានជួយស្វែងរកការងារឱ្យធ្វើ និងបង្កើតមុខ របរដោយខ្លួនឯងដល់នៅខេត្តរបស់ពួកគេ ។<br>- យុវវ័យចំនួន ៧១នាក់ (ស្រី០៧នាក់) ត្រូវបានតាមដានលើការងារឬការចាប់ផ្តើមអាជីវកម្មផ្ទាល់ខ្លួន ដោយក្រុមការងារនៅក្នុងខេត្តរបស់ពួកគេ ក្នុងឆ្នាំ២០១២ ។<br>- គ្រួសាររស់នៅតាមផ្លូវចំនួន ១០គ្រួសារ បានគាំទ្រឱ្យត្រឡប់ទៅស្រុកកំណើតវិញដូចជាខេត្តព្រៃវែង ខេត្តកំពង់ចាម ខេត្តបាត់ដំបង តាមរយៈការគាំទ្រអាជីវកម្មខ្នាតតូច ក្នុងឆ្នាំ២០១២ ។<br>- គ្រួសារចំនួន ២៥គ្រួសារ បានទទួលវគ្គបណ្តុះបណ្តាលស្តីពីអាជីវកម្មខ្នាតតូច និង៨គ្រួសារទទួលបានឧបត្ថម្ភអាជីវកម្មខ្នាតតូចនៅខេត្តរបស់ពួកគេក្នុងឆ្នាំ២០១២ ។<br>- យុវវ័យចំនួន ៣៩នាក់(ស្រី០៥នាក់) ទទួលបានគាំទ្រក្នុងការទទួលអត្តសញ្ញាណប័ណ្ណនៅខេត្តរបស់ពួកគេក្នុងឆ្នាំនេះ ។ |
| **៤.៥ ដោយមានការគាំ ទ្រពី** | ចំណូលរបស់អង្គការមិត្តសំឡាញ់តាមរយៈអាជីវកម្ម | ចំណូលរបស់អង្គការមិត្តសំឡាញ់តាមរយៈអាជីវកម្មៈ១,៥២៤,៧០២.៥១ដុល្លារ[1] |

1 (ចំណូលបានមកពីកម្មវិធីរបស់អង្គការមិត្តសំឡាញ់ ២១,០៧៩,០០ ដុល្លារមិនត្រូវបានដាក់បញ្ចូលទេ)

2 (ចំណាយរបស់កម្មវិធីរបស់អង្គការមិត្តសំឡាញ់ ២១,០៧៩ ,០០ ដុល្លារមិនត្រូវបានដាក់បញ្ចូលទេ)

| | | |
|---|---|---|
| **សង្គមអាជីវកម្មសង្គម កិច្ច** (FSB), **មិត្តសំឡាញ់** **មានចិរភាព ៥០%** | ចំណាយសរុបរបស់អង្គការមិត្តសំឡាញ់<br>និរន្តភាព: ៥០%<br>**សិប្បកម្មតាមផ្ទះ**<br>- គ្រួសារចំនួន១២៥ នឹងចូលរួមកម្មវិធីសិប្បកម្មតាមផ្ទះ ដោយមានកុមារចំនួន ៣៧០នាក់ បានទទួលផលពីគម្រោងនេះ ក្នុង១ឆ្នាំ ។<br>- គ្រួសារសិប្បកម្មតាមផ្ទះថ្មីចំនួន ២៥ គ្រួសារ និងអាណាព្យាបាលចំនួន ១២៥នាក់ នឹងទទួលបានការបណ្តុះបណ្តាលនៅមជ្ឈមណ្ឌលផលិតកម្ម (ប្រេន្ទអ៊ិនធីណាសិនណល និងអណ្តូង)<br>- យុវវ័យចំនួន២០នាក់នឹងទទួលបានគាំទ្រឱ្យមានការងារតាមរយៈអាជីវកម្មសង្គមកិច្ច (មិត្តសំឡាញ់ និងប្រេន្ទអ៊ិនធីណាសិនណល)<br>- ការលក់ផលិតផលពីសិប្បកម្មតាមផ្ទះក្នុងហាងលក់ទំនិញប្រេន្ទ អេន ស្តាហ្វ ហាង ទូចទូច ការលក់ក្នុងស្រុក និងអន្តរជាតិ នឹងបង្កើនប្រាក់ចំណូលចំនួន ៣០៧,០០០ ដុល្លារ ដែលមាននិរន្តភាពចំនួន៥០ %<br>**មជ្ឈមណ្ឌលផលិតកម្ម**<br>- អាណាព្យាបាលចំនួន ៧០នាក់ កំពុងទទួលបានការបណ្តុះបណ្តាលជំនាញសិប្បកម្មតាមផ្ទះ និងអាជីវកម្មខ្នាតតូច<br>- អាណាព្យាបាលចំនួន ១៥ នាក់ កំពុងធ្វើការបោះពុម្ភ<br>- **ក្រុមអាជីវកម្មខ្នាតតូច** កំពុងផ្តល់ការបណ្តុះបណ្តាល និងគាំទ្រគ្រួសារចំនួន ១៥០ (រួមបញ្ចូល៤០គ្រួសារថ្មី) ដើម្បីបង្កើតអាជីវកម្មផ្ទាល់ខ្លួន និងបង្កើនប្រាក់ចំណូលរបស់ពួកគេ ដោយមានកុមារចំនួន ៥៨០នាក់ដែលនឹងទទួលបានផលពីអាជីវកម្មនេះ | ចំណាយសរុបរបស់អង្គការ មិត្តសំឡាញ់ : ២,៧០៨,១៧៥,០០ ដុល្លារ[2]<br>និរន្តភាព: ៥៦%<br>**សិប្បកម្មតាមផ្ទះ**<br>- មាតាបិតាសិស្សចំនួន ១០៥ បានចូលរួមកម្មវិធីសិប្បកម្មតាមផ្ទះ ដោយមានកុមារចំនួន ៣១៤នាក់ (ស្រី ១៦៣នាក់) បានទទួលផលពីគម្រោងនេះ ។<br>- មានគ្រួសារសិប្បកម្មតាមផ្ទះថ្មីចំនួន១៨គ្រួសារ និងអាណាព្យាបាល១០៥នាក់ បានចូលរួមការបណ្តុះបណ្តាលនៅមជ្ឈមណ្ឌលផលិតកម្ម (ប្រេន្ទអ៊ិនធីណាសិនណលនិងអណ្តូង)<br>- អាណាព្យាបាលចំនួន ២២នាក់ បានទទួលការគាំទ្រឱ្យមានការងារតាមរយៈគម្រោងធុរៈកិច្ចសង្គម (មិត្តសំឡាញ់ និងប្រេន្ទអ៊ិនធីណាសិនណល) ក្នុងឆ្នាំ២០១២ ។<br>- គ្រួសារសប្បកម្មតាមផ្ទះចំនួន ០៣គ្រួសារ ដោយមានកុមារចំនួន ០៧នាក់ (ស្រី ០២នាក់) បានទទួលផលពីគម្រោងនេះ បានប្តូរទៅបង្កើតអាជីវកម្មផ្ទាល់ខ្លួនក្នុងឆ្នាំ ២០១២ ។<br>- ការលក់ផលិតផលសិប្បកម្មតាមផ្ទះក្នុង ហាងលក់ទំនិញប្រេន្ទអេនស្តាហ្វ ហាង ទូចទូច រួមទាំងការលក់ក្នុងស្រុក និងអន្តរជាតិ កំពុងបង្កើនប្រាក់ចំណូល បានចំនួន ២៧៩,១៩៨.៧៩ ដុល្លារ និងប្រាក់ចំណេញ ១២១,៣០៥.៤៣ ដុល្លារ ។<br>**មជ្ឈមណ្ឌលផលិតកម្ម**<br>- អាណាព្យាបាលចំនួន ៥០នាក់ បានទទួលការបណ្តុះបណ្តាលជំនាញសិប្បកម្មតាមផ្ទះ និងអាជីវកម្មខ្នាតតូច ។ - អាណាព្យាបាលចំនួន ០៤នាក់ បំរើការងារលើការបោះពុម្ព<br>- **ក្រុមអាជីវកម្មខ្នាតតូច** កំពុងផ្តល់ការបណ្តុះបណ្តាល ១៣៩គ្រួសារ រួមបញ្ចូល ៣៣ គ្រួសារថ្មីក្នុងឆ្នាំនេះ ដើម្បីបង្កើតអាជីវកម្មផ្ទាល់ខ្លួន និងបង្កើនប្រាក់ចំណូលរបស់ពួកគេ ដោយមានកុមារ ៥៤១នាក់ (ស្រី២២៩ នាក់) បានទទួលផលពីអាជីវកម្មនេះ ។ |

| | | |
|---|---|---|
| | - **កាហ្វេមិត្តសំឡាញ់** បង្កើតប្រាក់ចំណូលចំនួន ៣០,០០០ដុល្លារ ក្នុង១ឆ្នាំ<br>- **ផលិតផលមិត្តសំឡាញ់** (សៀវភៅរៀនធ្វើម្ហូបប្រហ្វេន្ស)នឹងអាចរកចំណូលបានចំនួន ៤៥,០០០ដុល្លារ ក្នុងមួយឆ្នាំ (កើនឡើង៤%)និងប្រាក់ចំណេញចំនួន ២៥, ០០០ ក្នុងមួយឆ្នាំ<br>- **ជំនាញវិជ្ជាជីវៈទាំងអស់** ដើរតួនាទីជាអាជីវកម្មសង្គមកិច្ច<br>- **កន្លែងធ្វើក្រចក** ស្ថិតនៅខាងក្នុង ហាងប្រហ្វេន្សអេនស្ដាស់ នៅលើផ្លូវ ១៣ ជិតភោជនីដ្ឋានប្រហ្វេន្ស<br>- **វិជ្ជាជីវៈភោជនីយដ្ឋាន** ចំនួន២ (សូមមើលៈ សកម្មភាព ៤.៣) )បានចូលរួមទៅក្នុងអាជីវកម្មសង្គមកិច្ច នឹងទទួលបានប្រាក់ចំណូល ១,១៥៤,០០០ ដុល្លារក្នុង ១ឆ្នាំ ដោយមានប្រាក់ចំណេញ ៣៣៨,០០០ដុល្លារ ក្នុង១ឆ្នាំ។ ភោជនីយដ្ឋានចំនួន ២ នឹងមាននិរន្តភាពរហូតដល់ ១០០% | - **កាហ្វេមិត្តសំឡាញ់** បង្កើតប្រាក់ចំណូលចំនួន ៤៩,៩៨៦.៨០ ដុល្លារ និងចំណេញ ២,៣១០,៩៤ដុល្លារ ។<br>- **ផលិតផលមិត្តសំឡាញ់** (សៀវភៅមុខម្ហូបនិងរបៀបធ្វើ) អាចរកចំណូលបានចំនួន ៣៦,៦៨៩.៣៨ ដុល្លារ និងប្រាក់ចំណេញចំនួន ២៧,៣៣៣.៦០ ដុល្លារ ។<br>- **ជំនាញវិជ្ជាជីវៈ**បានក្លាយជាធុរកិច្ចរួមមាន ថ្នាក់កាត់ដេរ ថ្នាក់ជួសជុលម៉ូតូ/ឡាន ថ្នាក់អគ្គិសនី ថ្នាក់អេឡិចត្រូនិច ថ្នាក់ផ្សារដែក ថ្នាក់ចុងភៅ ថ្នាក់កាត់សក់ និងថ្នាក់កែសម្ផស្ស បង្កើតបានប្រាក់ចំណូល ៤០,៩៣២.៨៤ដុល្លារ និងប្រាក់ចំណេញ ៩,៥១១.៤២ដុល្លារ ។<br>- **កន្លែងធ្វើក្រចក** បង្កើតបានប្រាក់ចំណូលចំនួន ១១,៥៥៥.០០ដុល្លារ និងខាតចំនួន -២,០២៨.២៣ដុល្លារ ។<br>- **វិជ្ជាជីវៈភោជនីយដ្ឋាន** ចំនួន២ (សូមមើលៈ សកម្មភាព៤.៣)បានចូលរួមក្នុងអាជីវកម្មសង្គមកិច្ច ទទួលបានប្រាក់ចំណូល ១,១៥១,៥២៩.៣៧ដុល្លារ និងប្រាក់ចំណេញ ២១០,០៤៧.២៣ដុល្លារ ។<br>**-ភោជនីដ្ឋានប្រហ្វេន្សៈ** ៦០៨,៩០០.៤០ដុល្លារ ប្រាក់ចំណូល និងប្រាក់ចំណេញ ១៣៨,៥៧៩.៤៧ដុល្លារ ។<br>**-ភោជនីដ្ឋានរំដេងៈ** ៥៤២,៦២៨.៩៧ដុល្លារ ប្រាក់ចំណូល និងប្រាក់ចំណេញ ៧១,៤៦៧.៧៦ដុល្លារ ។:<br>**ព្រឹត្តិការណ៍ និងកំណត់សម្គាល់ពិសេសៈ**<br>- គ្រួសារអាជីវកម្មខ្នាតតូចចំនួន ២ គ្រួសារ បានចូលរួមលក់ នៅក្នុងកម្មវិធីហាន់ហ្វែរ ដែលទទួលបានប្រាក់ចំណូលគួរសម នាថ្ងៃទី ២១ ខែ មករា ឆ្នាំ២០១២ ។ |

| | | |
|---|---|---|
| | | - ក្រុមសិប្បកម្មតាមផ្ទះបានបង្កើតផលិតផលថ្មីចំនួន ១0មុខ បន្ថែមទៀតនៅក្នុងឆ្នាំនេះ ។<br>- អ្នកគ្រប់គ្រងករណីចំនួន ១១នាក់( ស្រី0៦នាក់) បានចូលរួមវគ្គបណ្តុះបណ្តាលអាជីវកម្មខ្នាតតូច នៅអង្គការប្រេន្ទអ៊ិនធីណាសិនណល នាថ្ងៃទី 0៦ ខែមិថុនា ឆ្នាំ២0១២ ។<br>- ក្រុមសប្បកម្មតាមផ្ទះបានប្រើប្រាស់កាកសំណល់របស់ **Ezecom** ដូចជាក្រដាស និងបដារ ដើម្បីធ្វើជាសម្ភារៈដាក់តាំងនៅបន្ទប់បង្ហាញរបស់ក្រុមហ៊ុន **Ezecom** ។<br>- មិត្តសំឡាញ់បានផ្គត់ផ្គង់ផលិតផលសិប្បកម្មតាមផ្ទះទាន់ពេលដល់ហាងថ្មីនៃអង្គការប្រេន្ទអ៊ិនធីណាសិនណាល នៅសណ្ឋាគារអ៊ិនធើខន។ ក្រុមអាជីវកម្មសង្គម បានចូលរួមតាំងពិព័ណ េនៅក្នុងកម្មវិធី រាត្រីពណ៏បៃតង អង្គការម៉េឌីខាំ ឡឺកាហ្វេមិត្តសំឡាញ់ សណ្ឋាគារភ្នំពេញ សណ្ឋាគារអ៊ិនធើខន និង ភោជនីយដ្ឋានកាសូលីនា ។<br>- តូបលក់ផលិតផលនៅទួលទំពូង ទូចទូច បានធ្វើការផ្លាស់ប្តូរឈ្មោះទៅជា ប្រេន្ទអេនស្តាហ្វទួលទំពូងក្នុងឆ្នាំនេះ ។ ក្រុមការងារសិប្បកម្មតាមផ្ទះបានបង្ហាញពីរបៀបធ្វើគ្រាប់អង្កាំ និងមូលក្រដាស ដល់ក្រុមសិស្សចំនួន ១២0 នាក់មកពីសាលាអន្តរជាតិភ្នំពេញ និងបុគ្គលិក មកពីគំរោងProject Hammer ប្រទេសសឹង្ហបុរិ ។ |
| **៥.ក្រុមឯកទេសចំនួន ៨ ក្រុមកំពុងផ្តល់ការជួយគាំទ្រកម្មវិធីនៅត្រឹមឆ្នាំ២០១២** | | |
| **៥.១ ក្រុមឯកទេសលើការការពារកុមារ** | **លទ្ធផលរំពឹងទុកៈ**<br>- របាយការណ៍ស្តីពីការរំលោភបំពាន ១00ករណី នឹងត្រូវបានបំពេញ | **លទ្ធផលសំរេចបានៈ**<br>- របាយការណ៍ស្តីពីការរំលោភបំពាន ១៦៣ករណី ក្នុងនោះមាន ៤៨ករណីទទួលបានពីមន្ទីរសង្គមកិច្ចរាជធានីភ្នំពេញបានបំពេញទម្រង់បែបបទនិងគាំទ្រដោយបុគ្គលិកសង្គម អ្នកឯកទេសការពារសិទ្ធិកុមារ និងករណីធ្ងន់ធ្ងរបញ្ជូនទៅអាជ្ញាធរដើម្បីអន្តាគមន៏ ក្នុងឆ្នាំ ២0១២ ។ |

| | | |
|---|---|---|
| | **ការតាមដាន វាយតម្លៃ និងស្រាវជ្រាវ**<br>- ការវាយតម្លៃគោលការណ៍ការពារកុមារនៅក្នុងមណ្ឌលសំចត មជ្ឈមណ្ឌលអប់រំ មជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈ និងគ្រប់មណ្ឌលស្នាក់នៅបណ្តោះអាសន្ន ទាំងអស់<br>- ចងក្រងរបាយការណ៍សម្រាប់មិត្តសំឡាញ់ ម្ចាស់ជំនួយ និងរដ្ឋាភិបាល<br>- រៀបចំការស្ទង់មតិលើការស្នាក់នៅរបស់កុមារដែលស្នាក់នៅមណ្ឌលស្នាក់នៅបណ្តោះអាសន្នរបស់អង្គការមិត្តសំឡាញ់ រៀងរាល់ ៣ខែម្តង<br><br>**គាំទ្របច្ចេកទេស**<br>- បុគ្គលិក១00% នឹងទទួលការបណ្តុះបណ្តាល និងរំលឹកឡើងវិញលើគោលការណ៍ការពារសិទ្ធិកុមារ<br>- ការបោះឆ្នោតជ្រើសរើសតំណាងកុមារនឹងរៀបចំជារៀងរាល់៦ខែ ក្នុងឆ្នាំ<br>**ឧបករណ៍**<br>- នឹងធ្វើបច្ចុប្បន្នភាព និងអនុវត្តគោលការណ៍ការពារសិទ្ធិកុមារ<br>- គោលការណ៍ការពារសិទ្ធិកុមារ នឹងដាក់បង្ហាញនៅគ្រប់មណ្ឌលទាំងអស់<br>- ធានាថាឧបករណ៍ទាំងអស់មាននៅក្នុងមណ្ឌលនីមួយៗ | **ការតាមដាន វាយតម្លៃ និងស្រាវជ្រាវ**<br>- បានរៀបចំការសម្ភាសន៍កុមារ/យុវវ័យចំនួន ១២៧នាក់( ស្រី៣១នាក់) ស្តីពីបញ្ហា និងតម្រូវការរបស់ពួកគេ ដែលកំពុងស្នាក់នៅមណ្ឌលស្នាក់នៅបណ្តោះអាសន្ន ភោជនីដ្ឋានហ្វ្រេនឡ្យ ភោជនីដ្ឋានរំដេង ដោយអ្នកឯកទេសសុវត្ថិភាពកុមារក្នុងឆ្នាំ ២០១២ ។<br>- បានចងក្រងរបាយការណ៍ប្រចាំខែ ត្រីមាស និងប្រចាំឆ្នាំ ជូនមិត្តសំឡាញ់ ។<br>- បានរៀបចំការសម្ភាសន៍កុមារ/យុវវ័យចំនួន 0៦នាក់ ស្តីពីសេវាកម្មរបស់មិត្តសំឡាញ់ តម្រូវការរបស់ពួកគេ និងការការពារកុមារ រៀបចំដោយជំនួយការបច្ចេកទេសរបស់ហ្វ្រេនឡ្យអ៊ិនធឺណាស៊ិនណល និងអ្នកឯកទេសការពារកុមារ នាថ្ងៃទី ២១ ខែមីនា ឆ្នាំ ២០១២ ។<br><br>**គាំទ្របច្ចេកទេស**<br>- បុគ្គលិក ៨៦% បានទទួលការបណ្តុះបណ្តាល និងរំលឹកឡើងវិញដើម្បីពង្រឹងដំណើរការនៃការអនុវត្តន៍គោលការណ៍ ការពារសិទ្ធិកុមារ និងធានាសុវត្ថិភាពដល់កុមារ<br>- បានចុះមូលដ្ឋានចំនួន ២៩៦ដង មជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈ មជ្ឈមណ្ឌល អប់រំ មណ្ឌលសំចត និងនៅតាមផ្ទះ ។<br>- បុគ្គលិកកល្យាណមិត្តចោមចៅចំនួន១៣នាក់( ស្រី0២នាក់) បានទទួលវគ្គបណ្តុះបណ្តាលស្តីពីសៀវភៅណែនាំសិទ្ធិកុមារ នៅហ្វ្រេនឡ្យអ៊ិនធឺណាស៊ិនណល នាថ្ងៃទី0៦ ខែកក្កដា ឆ្នាំ២០១២ ។<br>- បុគ្គលិកមណ្ឌលស្នាក់នៅបណ្តោះអាសន្នចំនួន ១៣នាក់ ( ស្រី0៤នាក់) បានទទួលវគ្គរំលឹកឡើងវិញស្តីពីសិទ្ធិកុមារនៅ មណ្ឌលស្នាក់នៅបណ្តោះអាសន្ន នាថ្ងៃទី0២ ខែ សីហា ឆ្នាំ២០១២ ។ |

| | | |
|---|---|---|
| | | - បុគ្គលិកចំនួន ១០៨នាក់ បានទទួលវគ្គបណ្តុះបណ្តាលស្តីពីគោលការណ៍ការពារ សិទ្ធិ កុមារ និងបុគ្គលិក ៨៦នាក់ បានទទួលវគ្គបណ្តុះបណ្តាលស្តីពីទម្រង់នៃការរំលោភបំពានកុមារ នៅក្លឹបប្រេន្យក្នុងឆ្នាំ ២០១២ ។<br>- កុមារ/យុវវ័យចំនួន ៥៦៨នាក់( ស្រី២២០នាក់) បានចូលរួមបោះឆ្នោតជ្រើសរើសតំណាងកុមារ នៅក្លឹបប្រេន្យ ហើយមានកុមារចំនួន ១៣នាក់ ត្រូវជ្រើសរើសជាតំណាងកុមារក្នុងឆ្នាំ ២០១២ ។<br>**ឧបករណ៍**<br>- គោលនយោបាយសម្រាប់ការពារកុមារ បទបញ្ជាផ្ទៃក្នុង និងប្រពន្ធ័របាយការណ៍បានបិតនៅលើជញ្ជាំងនៃមណ្ឌលអង្គការមិត្តសំឡាញ់ទាំងអស់ ។<br>- បានធ្វើបច្ចុប្បន្នភាពលើបទបញ្ជាផ្ទៃក្នុងសម្រាប់មជ្ឈមណ្ឌលអប់រំ ដោយមានការចូលរួមពីកុមារនិងយុវវ័យ ។<br>**ព្រឹត្តិការណ៍ និងកំណត់សម្គាល់ពិសេសៈ**<br>- បានចូលរួមសិក្ខាសាលា ស្តីពីបទដ្ឋានអប្បរមាសម្រាប់កុមារដែលអនាថងាយរងគ្រោះនៅក្រសួងសង្គមកិច្ច នាថ្ងៃទី ០៨ ខែមថុនា ឆ្នាំ២០១២ ។<br>- បានចូលរួមប្រជុំស្តីពីយុទ្ធសាស្រ្តថ្មី នៃបណ្តាញអង្គការដើម្បីបោះឆ្នោតជ្រើសរើស សមាជិកក្រុមប្រឹក្សាភិបាលរបស់អង្គការ គណៈកម្មាការលប់បំបាត់ពេស្យាចារ ការរំលោភ និងជួញដូរកុមារនៅកម្ពុជា និងទប់ស្កាត់ការគេងប្រវញ្ចផ្លូវភេទកុមារ នៅអង្គការគណៈកម្មាការ លប់បំបាត់ពេស្យាចារ ការរំលោភ និងជួញដូរកុមារនៅកម្ពុជាក្នុងឆ្នាំនេះ ។<br>- បានចូលរួមកិច្ចប្រជុំលើកំរង់សំណួរ ស្តីពីសិទ្ធិកុមារសម្រាប់ធ្វើការតាមដាន រៀបចំផែនការយុទ្ធសាស្រ្តឆ្នាំ២០១៣ និងមធ្យោបាយនៃការការពារកុមារ ដោយអនុលោមទៅតាម |

| | | |
|---|---|---|
| | | អនុសញ្ញាស្តីពីសិទ្ធិកុមារ នៅសម្ពន្ធអង្គការមិនមែនរដ្ឋាភិបាលដើម្បី សិទ្ធិកុមារក្នុងឆ្នាំនេះ ។<br>- បានចូលរួមសិក្ខាសាលាលើការពង្រាងផែនទី និងរបាយការណ៍ប៉ាន់ប្រមាណស្តីពីសិទ្ធិនៃជនរងគ្រោះពីការជួញដូរកុមារ នៅក្រសួងស.អ.យ ថ្ងៃទី២៣ ខែសីហា ឆ្នាំ២០១២ ។<br>- បានចូលរួមកិច្ចប្រជុំស្តីពីការស្រាវជ្រាវលើការការពារកុមារនៅដេប៉ាតឺម៉ង់នៃការងារសង្គមនៃសកលវិទ្យាល័យភូមិន្ទភ្នំពេញ នាថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០១២ ។<br>- បានចូលរួមកិច្ចប្រជុំស្តីពី អ្នកការពារសិទ្ធិមនុស្ស និងការបញ្ចេញសិទ្ធិសេរីភាព នៅសណ្ឋាគារអ៊ិនធើរៀលហ្គោឌិន រៀបចំដោយមណ្ឌលសិទ្ធិមនុស្សកម្ពុជា នាថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ ២០១២ ។<br>- បានចូលរួមកិច្ចប្រជុំស្តីពីលទ្ធផលនៃការស្ទង់មតិ និងអនុសាសន៍ ពាក់ព័ន្ធទៅនឹងអនុសញ្ញាស្តីពីសិទ្ធិកុមាររបស់អង្គការសហប្រជាជាតិ និងបានរៀបចំផែនការសកម្មភាពសម្រាប់ធ្វើការតាមដាន នៅសម្ពន្ធអង្គការមិនមែនរដ្ឋាភិបាលដើម្បីសិទ្ធិកុមារ នាថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០១២ ។ |
| **៥.២ ក្រុមឯកទេសវេជ្ជសាស្ត្រ** | **លទ្ធផលរំពឹងទុកៈ**<br>- សេវាព្យាបាលនិងសង្គ្រោះបឋមចំនួន ៨៥,000 នឹងផ្តល់ជូនកុមារ/យុវវ័យ ក្នុងនោះមានសេវាសម្រាប់អ្នកប្រើប្រាស់គ្រឿងញៀន/អ្នកប្រើប្រាស់គ្រឿងញៀនដោយចាក់ចំនួន ២៣,000 សេវា<br>- កុមារ/យុវវ័យចំនួន ៨៥0នាក់ នឹងបញ្ជូនទៅនៅមន្ទីរពេទ្យ<br>- កុមារ/យុវវ័យផ្ទុកមេរោគអេដស៍ និងជម្ងឺអេដស៍ចំនួន ១0នាក់ នឹងទទួលបានការព្យាបាលនៅមន្ទីរពេទ្យ<br>- អាណាព្យាបាលដែលផ្ទុក មេរោគអេដស៍ និងជម្ងឺអេដស៍ចំនួន ៣0នាក់ នឹងទទួល | **លទ្ធផលសំរេចបានៈ**<br>- សេវាព្យាបាល និងសង្គ្រោះបឋមចំនួន ៩៧,០៨៧ បានផ្តល់ជូនកុមារ/យុវវ័យក្នុង នោះមានសេវាសម្រាប់អ្នកប្រើប្រាស់គ្រឿងញៀន/ អ្នកប្រើប្រាស់គ្រឿងញៀនដោយចាក់ចំនួន ២៧,១៦៣ សេវា ។<br>- កុមារ/យុវវ័យចំនួន ៧២៧នាក់ បានបញ្ជូនទៅនៅព្យាបាលមន្ទីរពេទ្យ<br>- កុមារផ្ទុកមេរោគអេដស៍ និងជម្ងឺអេដស៍ចំនួន 0៦នាក់ បានទទួលការព្យាបាលនៅមន្ទីរពេទ្យ ក្នុងឆ្នាំ២០១២ ។<br>- អាណាព្យាបាលដែលផ្ទុកមេរោគអេដស៍ និងជម្ងឺអេដស៍ចំនួន២៥នាក់ បានទទួលការ |

| | | |
|---|---|---|
| | បានការព្យាបាលនៅមន្ទីរពេទ្យ<br>- កុមារ/យុវវ័យចំនួន ៣០០នាក់ នឹងទទួលការព្យាបាលជម្ងឺកាមរោគ<br>- អាណាព្យាបាលចំនួន ៩០នាក់ នឹងទទួលការព្យាបាលជម្ងឺកាមរោគ<br><br>**ការតាមដាន វាយតម្លៃ និងស្រាវជ្រាវ**<br>- ប្រព័ន្ធត្រួតពិនិត្យនិងប្រមូលទិន្នន័យគឺជាសូចនាករលក្ខណៈស្តង់ដា នៃកម្មវិធីប្រែឡអ៊ិនធឺណាសិនណាលសម្រាប់សកម្មភាពសុខាភិបាល<br>- ការវាយតម្លៃលើការថែរក្សាផ្នែកសុខភាពនៅក្នុងគម្រោងទាំងអស់មានកិច្ចសហប្រតិបត្តិការយ៉ាងជិតស្និទជាមួយអ្នកឯកទេសហ៊ីវ/អេដស៍ក្នុងរយៈពេល១ឆ្នាំ<br>- ចងក្រងរបាយការណ៏សម្រាប់មិត្តសំឡាញ់ ម្ចាស់ជំនួយ និងរដ្ឋាភិបាល<br>**គាំទ្របច្ចេកទេស**<br>- បុគ្គលិកវេជ្ជសាស្ត្រទាំងអស់ នឹងទទួលបានការបណ្តុះបណ្តាលយ៉ាងទៀងទាត់<br>- ជំនួយបច្ចេកទេស នឹងផ្តល់ជារៀងរាល់សប្តាហ៏តាមរយៈការងារនៅតាមមូលដ្ឋានជាមួយក្រុមទាំងអស់<br>- ពង្រឹងកិច្ចសហការរវាងបុគ្គលិកសុខាភិបាល និងអ្នកគ្រប់គ្រងករណី<br>- ពិនិត្យឡើងវិញ និងបញ្ជាទិញសម្ភារៈវេជ្ជសាស្ត្រតាមតម្រូវការរបស់ក្រុមការងារ<br>**ឧបករណ៏**<br>- សៀវភៅណែនាំ នឹងរៀបចំ អនុវត្ត និងធ្វើបច្ចុប្បន្នភាពជាទៀងទាត់<br>**ដៃគូ** | ព្យាបាលនៅមន្ទីរពេទ្យ ក្នុងឆ្នាំ២០១២ ។<br>- កុមារ/យុវវ័យចំនួន ៣០៣នាក់ បានទទួលការព្យាបាលជម្ងឺកាមរោគ ពីគ្លីនិករបស់មិត្តសំឡាញ់ទាំងអស់ ។<br>- អាណាព្យាបាលចំនួន ២៧០នាក់ បានទទួលការព្យាបាលជម្ងឺកាមរោគពីគ្លីនិករបស់មិត្តសំឡាញ់ទាំងអស់ ។<br><br>**ការតាមដាន វាយតម្លៃ និងស្រាវជ្រាវ**<br>- តាមរយៈការចុះមូលដ្ឋានយ៉ាងទៀងទាត់ និងតាមដានពីអ្នកឯកទេស គ្លីនិកទាំង អស់មានអនាម័យ ល្អបន្ទប់ស្អាត ទម្រង់អង្កេតរបស់កុមារត្រូវបានបំពេញ និង កន្លែងទុកថ្នាំត្រូវបានរៀបចំយ៉ាងរៀបរយ ។<br>- បានត្រួតពិនិត្យសុខភាពកុមារ/យុវវ័យ ដែលចូលរៀននៅអង្គការមិត្តសំឡាញ់ និងពេលបញ្ជូនទៅគ្រួសារ ឬប្រកបមុខរបរមានចំនួន២៤១នាក់ ។<br>- បានចងក្រងរបាយការណ៏ប្រចាំខែ ត្រីមាស និងប្រចាំឆ្នាំដើម្បីផ្ញើរជូនមិត្តសំឡាញ់ មន្ទីរសុខាភិបាល រាជធានីភ្នំពេញ និងក្រសួងសុខាភិបាល ។<br>- បានរៀបចំកំរងសំណួរសម្រាប់ធ្វើវាយតម្លៃលើសេវាសុខភាពនៃអង្គការមិត្តសំឡាញ់ជាមួយបុគ្គលិកពេទ្យ ដោយមានកិច្ចសហការជាមួយអ្នកស្ម័គ្រចិត្តនៃអង្គការ ប្រែឡអ៊ិនធឺណាសិនណាល ។<br>- បានដឹកនាំធ្វើការវាយតម្លៃលើសេវាសុខភាព នៃអង្គការមិត្តសំឡាញ់ជាមួយបុគ្គលិក ពេទ្យចំនួន១៤ នាក់ (ស្រី០៤នាក់) ដោយមានកិច្ចសហការជាមួយអ្នកស្ម័គ្រចិត្ត នៃអង្គការប្រែឡអ៊ិនធឺណាសិនណាល ។<br>- បុគ្គលិកសង្គម ៤៧នាក់ បានចូលរួមវគ្គបណ្តុះបណ្តាល ស្តីពីសុខភាពមាត់ធ្មេញ និង |

| | | |
|---|---|---|
| | - បង្កើត ប្រើប្រាស់ និងធ្វើបច្ចុប្បន្នភាពបញ្ជីសេវាកម្មជារៀងរាល់ឆ្នាំ និងចែករំលែកជាមួយក្រុមទាំងអស់<br>- បុគ្គលិកអង្គការដៃគូចំនួន ៣៥នាក់ នឹងត្រូវបានស្វែងរក និងបណ្តុះបណ្តាលក្នុងមួយឆ្នាំ<br>- ប្រសិទ្ធិភាពនៃកិច្ចសហការជាមួយរដ្ឋាភិបាល | ជម្ងឺគ្រុនចាញ់ ។<br>- បុគ្គលិកពេទ្យចំនួន ១៤នាក់( ស្រី ០៤នាក់) បានរួមវគ្គបណ្តុះបណ្តាលស្តីពីសង្គ្រោះ បឋម គរុកោសល្យនៃការបង្រៀន ប្រតិកម្មស្បែក ចិត្តសាស្ត្រសង្គម មូលដ្ឋានគ្រឹះនៃគ្រឿងញៀន សុខភាពបន្តពូជ កាមរោគ និង មេរោគអេដស៍/ជំងឺអេដស៍ ។<br>**គាំទ្របច្ចេកទេស**<br>- ករណីមេរោគអេដស៍/ជម្ងឺអេដស៍ចំនួន ១៨ករណីរួមមានៈ ដុះដុំសាច់ខួរក្បាល ដុំសាច់នៅខ្នង បញ្ហាត្រចៀក បញ្ហាខួរក្បាល បញ្ហាភ្នែក ករណីកុមារ ០១នាក់ត្រូវបានគេបោះបង់ យុវវ័យប្រើប្រាស់គ្រឿងញៀនហើមជើង យុវវ័យរះកាត់ដៃ និង បញ្ហាប្រតិកម្មស្បែក ទទួលបានគាំទ្រ និងបញ្ជូនទៅមន្ទីរ ពេទ្យកាល់ម៉ែត មជ្ឈមណ្ឌលស្ថានីតិសម្បទាគៀនឃ្លាំង មិត្តភាពខ្មែរ-សូវៀត មន្ទីរពេទ្យក្រុង មជ្ឈមណ្ឌលប្រយុទ្ធប្រឆាំង និងជំងឺអេដស៍សើស្បែក ។<br>- បានចុះមូលដ្ឋានចំនួន ២០០ដង ក្នុង៥តំបន់ រួមបញ្ចូលទាំងមណ្ឌលស្នាក់នៅបណ្តោះអាសន្ន ផ្ទះបៃតង និងមណ្ឌលសំចតចល័តទាំង ២ផង ដើម្បីជួយអ្នកគ្រប់គ្រង់ករណី និងប្រធានតំបន់ ក្នុងការគាំទ្រផ្នែកសុខភាពដល់កុមារ/យុវវ័យ និងគ្រួសារតាមតំបន់គោលដៅ ។<br>- គ្រួសារដែលរស់នៅជាមួយមេរោគអេដសន៏ និងជម្ងឺអេដស៍ចំនួន ៣០គ្រួសារ បានទទួលព័តិមានពីការថែរក្សាសុខភាព ពីអ្នកឯកទេស វេជ្ជសាស្ត្រ នៅសហគមន៏អណ្តូង និងតំបន់វត្តភ្នំ ។<br>- បានផ្តល់ពិត័មានស្តីពីការការពារនិងការទប់ស្កាត់នៃជម្ងឺពងបែកលើដៃជើង និងមាត់ (EV71) ដល់អ្នកទទួលផលទាំងអស់ទាំងនៅតាមផ្ទល់ មណ្ឌលអប់រំ និងមណ្ឌលស្នាក់ |

| | | |
|---|---|---|
| | | នៅបណ្តោះ អាសន្ន ។<br>**ឧបករណ៏**<br>- គោលការណ៏ណែនាំលើសេវាការព្យាបាលបឋម បានឯកភាពដោយនាយិកាកម្មវិធី ហើយបានចែករំលែកដល់បុគ្គលិកពេទ្យទាំងអស់ ដើម្បីមានភាពងាយស្រួលក្នុងការអនុវត្ត។<br>- បានធ្វើបច្ចុប្បន្នភាពលើទម្រង់ពិនិត្យសុខភាព និងបញ្ជីថ្នាំពេទ្យ នៅផ្ទះបៃតង ។<br>- បានពង្រាងគោលការណ៏ព្យាបាលអ្នកញៀនស្រាររួចនិងអនុវតនៅផ្ទះបៃតង ។<br>- មិត្តសំឡាញ់ បានធ្វើការដេញថ្លៃរួចលើសេវាផ្គត់ផ្គង់ថ្នាំពេទ្យសម្រាប់ឆ្នាំ ២០១៣ នាថ្ងៃទី ១២ ខែធ្នូ ឆ្នាំ២០១២។<br>**ដៃគូ**<br>**<u>ការប្រជុំ និងកិច្ចសហការជាមួយរដ្ឋាភិបាល/អង្គការដៃគូ:</u>**<br>- ដោយមានកិច្ចសហការពីអង្គការប្រេន្ទអ៊ិនធឺណាសិនណលបានធ្វើទស្សនកិច្ចនៅតាមអង្គការ និងមន្ទីរពេទ្យជយ័ជំនះ ចំនួន ៥ រួមមាន មជ្ឈមណ្ឌលវះកាត់កុមារ កែវសាន្ត មជ្ឈមណ្ឌលបង្ការពិការភាពកម្ពុជា មណ្ឌលវេជ្ជសាស្ត្រហេលប្រ៊ុន មជ្ឈមណ្ឌលវិភាគរូបភាពវេជ្ជសាស្ត្រ និងមជ្ឈមណ្ឌលអ៊ិនអេសស៊ី ដើម្បីដាក់បញ្ចូលនៅទៅក្នុងបញ្ជីសេវាកម្ម។<br>- បានសហការជាមួយវេជ្ជបណ្ឌិត នៅមជ្ឈមណ្ឌលស្ថានីតិសម្បទាគៀនឃ្លាំង មន្ទីរពេទ្យកាល់ម៉ែត មន្ទីរពេទ្យគន្ធបុប្ផា មន្ទីរពេទ្យមិត្តភាពខ្មែរ-សូវៀត ដើម្បីគាំទ្រ និងព្យាបាលដល់កុមារនិងយុវវ័យដែលឥតបង់ថ្លៃ។<br>- បានចូលរួមកិច្ចប្រជុំប្រចាំខែជាមួយអង្គការម៉ៃឌីខាំដើម្បីចែករំលែកព័តិមានពាក់ព័ន្ធទៅនឹង |

| | | |
|---|---|---|
| | | បញ្ហាផ្នែកសុខភាព ហើយបានសហការជាមួយអង្គការដៃគូផ្សេងទៀត នៅការិយាល័យអង្គការម៉ែឌិខា។<br>- កុមារនៅមជ្ឈមណ្ឌលអប់រំចំនួន ២៨៤នាក់(ស្រី ១១៣នាក់) បានគាំទ្រលើការព្យាបាល និងថែទាំសុខភាពមាត់ធ្មេញពីអង្គការ One 2 One នៅមន្ទីរពេទ្យព្រះកិតុមាលា រៀងរាល់ថ្ងៃពុធ។<br>- កុមារចំនួន ៦១នាក់ (ស្រី ២០នាក់) បានទទួលថ្នាំ និង ថ្នាំព្រូនពីកម្មវិធីការ ចាក់ថ្នាំបង្ការមេរោគថ្នាក់ជាតិ ។<br>**ព្រឹត្តិការណ៍ និងកំណត់សម្គាល់ពិសេស:**<br>- មន្ទីរពេទ្យមិត្តភាពខ្មែរ-សូវៀត នៅបន្តការចុះតម្លៃ ២០% និងមន្ទីរពេទ្យបង្អែកក្រុង ១០% ចំពោះការព្យាបាលអតិថិជនរបស់អង្គការមិត្តសំឡាញ់។<br>- គ្រួសារដែលរស់នៅសហគមន៍អណ្តូងចំនួន ៦០គ្រួសារ បានទទួលព័ត៌មានពីការការពារជម្ងឺគ្រុនឈាមពីបុគ្គលិកអណ្តូង ។ |
